**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 07-Aug-2013, 15:35
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

**សំណើរបស់សហព្រះរាជអាជ្ញា សុំការបំភ្លឺអំពីការរកឃើញទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម ដូចបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១**

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ចម្លងជូន:** |
|---|---|---|
| **សហព្រះរាជអាជ្ញា:** | **អង្គជំនុំជម្រះសាលាដំបូង:** | **ជនជាប់ចោទ:** |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | ខៀវ សំផន |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Jean-Marc LAVERGNE | **មេធាវីការពារក្ដីជនជាប់ចោទ:** |
| | ចៅក្រម យូរ ឧត្ដរា | លោក សុន អរុណ |
| | | លោក Victor Koppe |
| | **សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:** | លោក គង់ សំអុន |
| | | លោក Jacques VERGÈS |
| | ពេជ អង្គ | លោក Arthur VERCKEN |
| | Elisabeth SIMONNEAU FORT | Anta GUISSÉ |

## I. សេចក្តីផ្តើម

១- ភាគី និងអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសវនាការនាខែចុងក្រោយ បានធ្វើការប្រាស្រ័យផ្លាស់ប្តូរគ្នាមួយចំនួនទាក់ទងនឹងគោលបំណងសម្រាប់ភ័ស្តុតាង នៃគោលនយោបាយសហកម្មឧក្រិដ្ឋកម្មរួម (JCE) ដែលមិនជាប់ទាក់ទងដោយផ្ទាល់ទៅនឹងបទចោទនៅក្នុងសំណុំរឿង ០០២/០១ ដែលអាចត្រូវបានទទួលយក។ តាមរយៈការឆ្លើយឆ្លងគ្នានេះ សហព្រះរាជអាជ្ញាដាក់ជូនសំណើសុំការបំភ្លឺនេះទាក់ទិននឹងការរកឃើញផ្នែកអង្គហេតុ និងការសន្និដ្ឋានអង្គច្បាប់ ដែលនឹងត្រូវធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង ស្តីពីគោលនយោបាយ JCE ដែលមិនទាក់ទងនឹងបទចោទដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ០០២/០១។

## II.ប្រវត្តិនីតិវិធី

២- នៅឯកិច្ចប្រជុំរៀបចំសវនាការ នាខែមេសា ឆ្នាំ២០១១ និងនៅក្នុងសវនាការបឋម នាខែមិថុនា ឆ្នាំ២០១១ ដែលបានធ្វើឡើងនៅមុនពេល ការបំបែកសំណុំរឿង០០២ និងការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីលើភ័ស្តុតាង អង្គជំនុំជម្រះសាលាដំបូងបានណែនាំដល់ភាគីនានាថា ដំណាក់កាលដំបូងនៃសវនាការលើសំណុំរឿង០០២ នឹងលើកឡើងអំពី៖ រចនាសម្ព័ន្ធនៃកម្ពុជាប្រជាធិបតេយ្យ, តួនាទីរបស់ជនជាប់ចោទ (ទាំងនៅមុន និងទាំងក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ), រួមមាន "ក្របខណ្ឌនៃសិទ្ធិអំណាចរបស់គាត់ និងខ្សែបណ្តាញទាក់ទង" និង "គោលនយោបាយ [ទាំងប្រាំ] នៃរបបកម្ពុជាប្រជាធិបតេយ្យ ស្តីពីបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ផង[1]។ នៅខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះបានចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើសំណុំរឿងនេះ ឲ្យទៅជាសវនាការច្រើនឈុត ដែលសវនាការទីមួយ ក្នុងចំណោមសវនាការច្រើនឈុតនោះ នឹងនៅតែគ្របដណ្តប់ទៅលើការសួរដេញដោលលើបញ្ហានានានៃដំណាក់កាលដំបូងខាងលើនោះដដែល ប៉ុន្តែបើមិនដូច្នោះទេ គួរត្រូវបានកម្រិតទៅតាមការយល់ឃើញរបស់ខ្លួនស្តីពីមូលដ្ឋានឧក្រិដ្ឋកម្ម ត្រឹម

[1] **E1/2.1** ប្រតិចារឹកនៃកិច្ចប្រជុំរៀបចំសវនាការ, ៥ មេសា ២០១១, ១១.៣៤.៥០ ដល់ ១១.៣៧.១០។ **E1/4.1** ប្រតិចារឹកនៃសវនាការបឋម, ២៧ មិថុនា ២០១១, ០៩.១៨.២៥ ដល់ ០៩.២២.១០។ **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង, ២២ កញ្ញា ២០១១, កថាខណ្ឌទី១។

តែការជម្លៀសប្រជាជនដោយបង្ខំចំនួនពីរលើក[2]។ អង្គជំនុំជម្រះក៏បានណែនាំដល់ភាគីនានាផងដែរថា ទីកន្លែងឧក្រិដ្ឋកម្មបន្ថែមទៀត នៅក្នុងសំណុំរឿង០០២ អាចនឹងត្រូវបានដាក់បន្ថែមចូលទៅក្នុងសវនាការទីមួយ អាស្រ័យទៅលើ មេធាវីការពារក្តីមានឱកាសគ្រប់គ្រាន់ក្នុងការត្រៀមរៀបចំ និងគ្រប់ភាគីទាំងអស់ត្រូវបានគេជូនដំណឹងយ៉ាងគ្រប់គ្រាន់[3]។

៣- នៅមុនការចាប់ផ្តើមសវនាការទីមួយ អង្គជំនុំជម្រះបានផ្តល់ជូននូវការបញ្ជាក់បន្ថែមដូចតទៅ ស្តីពីវិសាលភាពដែលគោលនយោបាយនានាមិនមានការពាក់ព័ន្ធភ្លាមៗទៅនឹងទីកន្លែងឧក្រិដ្ឋកម្មទាំងឡាយនៅក្នុងសំណុំរឿង០០២/០១ ដែលនឹងត្រូវបានសួរដេញដោលនៅក្នុងសវនាការនេះថា៖

> *ទាក់ទងនឹងការសួរដេញដោលទៅលើគោលនយោបាយផ្សេងៗ ក្រៅពីគោលនយោបាយដែលជាប់ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំ គោលបំណងនៃការបញ្ចូលការលើកឡើងគោលនយោបាយផ្សេងៗទាំងនោះនៅក្នុងសវនាការដំណាក់កាលដំបូង គឺដើម្បីឱ្យមានលទ្ធភាពបង្ហាញពីរបៀបដែលគោលនយោនាយ ត្រូវបានបង្កើតឡើង។ ដូច្នេះ អ្វីដែលរំពឹងទុក គឺការបង្ហាញជាទូទៅពីគោលនយោបាយទាំងប្រាំ ទោះបីជាបញ្ហាជាក់ស្តែងសម្រាប់សួរដេញដោលនៅក្នុងសវនាការដំណាក់កាលដំបូងត្រូវបានកម្រិតនៅត្រឹមការជម្លៀសប្រជាជនដោយបង្ខំ(ដំណាក់កាលទី១ និងទី២) យ៉ាងណាក៏ដោយ។ នឹងមិនមានការពិនិត្យលើការអនុវត្តគោលនយោបាយផ្សេងៗ ក្រៅពីគោលនយោបាយដែលពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំ (ដំណាក់កាលទី១ និង ទី២)[4] ។*

៤- អង្គជំនុំជម្រះសាលាដំបូង ក្រោយមកបានពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១ តាមរយៈការដាក់បញ្ចូលការសម្លាប់មនុស្សនៅទីតាំងទួលពោធិ៍ជ្រៃ ដែលបានកើតឡើងភ្លាមៗ បន្ទាប់ពីការរំដោះទីក្រុង

---

[2] **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង, ២២ កញ្ញា ២០១១, កថាខណ្ឌទី១ និង ៥។

[3] **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង, ២២ កញ្ញា ២០១១, កថាខណ្ឌទី៦។

[4] **E141** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រី*ជាន់ខ្ពស់*ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១១, ១៧ វិច្ឆិកា ២០១១, ទំព័រទី២។

ភ្នំពេញ[5]។ ឧក្រិដ្ឋកម្មទាំងនេះចាំបាច់តម្រូវឲ្យមានការពិចារណាពីគោលនយោបាយ JCE ទាក់ទងនឹងខ្មាំង និងជាពិសេស ការកំណត់គោលដៅចំពោះអតីតទាហាន និងមន្ត្រី លន់ នល់។

៥- នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា ខ្លួនអាច "ធ្វើការពិចារណាទៅលើតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទ ទាក់ទិនទៅនឹងគោលនយោបាយទាំងអស់ដែលជាប់ពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល ប៉ុន្តែនឹងធ្វើការពិចារណាលើអង្គហេតុលម្អិត នៅក្នុងការជំនុំជម្រះដំណាក់កាលដំបូង" ចំពោះគោលនយោបាយដែលបានដាក់បញ្ចូលរួចហើយ[6]។

៦- នៅក្នុងសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីររបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់អះអាងសាជាថ្មី "ចាប់តាំងពីពេលចាប់ផ្តើមដំបូងថា អង្គជំនុំជម្រះបានសម្រេចថា គ្រប់ភាគីទាំងអស់អាចនាំភស្តុតាងទាក់ទងទៅនឹងតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទទាំងអស់ដែលពាក់ព័ន្ធនឹងរាល់គោលនយោបាយទាំងអស់ ក្នុងសម័យកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ"[7]។ ទាក់ទងចំណុចនេះ សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរបានលើកជាសម្អាងនៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលគ្របដណ្តប់ទៅគោលនយោបាយ JCE ទាំងប្រាំ ទោះបីជាកថាខណ្ឌទាំងឡាយដែលក្នុងនោះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា នឹងនាំឲ្យមាន*ការរកឃើញមួយចំនួន* ដែលទាក់ទងតែទៅនឹងគោលនយោបាយដែលពាក់ព័ន្ធនឹងការចោទប្រកាន់នានានៅក្នុងសំណុំរឿងលេខ០០២/០១ក៏ដោយ[8]។ អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ថា ដោយផ្អែកលើមូលដ្ឋាននៃការចោទប្រកាន់នានាដែលបានដាក់បញ្ចូលនៅក្នុងសំណុំរឿងលេខ០០២/០១ គេនឹងអាចពិនិត្យមើលបានតែ "ទៅលើប្រធានបទខ្លីៗសំខាន់ៗចំនួនប្រាំនៃដីកាដំណោះស្រាយនៃសំណុំ

[5] **E163/5** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុង*វិសាលភាព*នៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាផរមាន, ៨ តុលា ២០១២។

[6] **E124/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញ អំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំ*ពាក់ព័ន្ធនានា* ព្រមទាំងឧបសម្ព័ន្ធ, ១៨ តុលា ២០១១, ត្រង់កថាខណ្ឌទី១១។

[7] ឯកសារលេខ **E284** សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿងលេខ ០០២ បន្ទាប់ពីមានសេចក្តីសំរេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា ២០១៣, កថាខណ្ឌទី១១៧។

[8] *ឯកសារដដែលដូចខាងលើ*, ត្រង់កំណត់សម្គាល់ជើងទំព័រ២១៥។

រឿងលេខ០០២ប៉ុណ្ណោះ គឺមានន័យថា ការជម្លៀសចេញដោយបង្ខំ និងការសម្លាប់ពួកអ្នកដែលគេអះអាងថា ជាខ្មាំងនៃរបប"[9] ប៉ុន្តែថា វិសាលភាពនៃសវនាការដែលបានកំណត់រួច យ៉ាងណាមិញនឹង "ផ្តល់លទ្ធផលដល់សហព្រះរាជអាជ្ញាក្នុងការដាក់នូវបទល្មើសទាំងនេះ នៅក្នុងរង្វង់នៃបរិបទដ៏ទូលំទូលាយជាងនេះនៃសហកម្មឧក្រិដ្ឋកម្មរួម ដែលក្នុងនោះ ជនជាប់ចោទទាំងអស់សុទ្ធតែត្រូវបានចោទប្រកាន់ថាបានចូលរួម"[10]។

៧- នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងជាថ្មីម្តងទៀតបានសម្រេចថាភ័ស្តុតាងពាក់ព័ន្ធនឹងគោលនយោបាយទាំងឡាយដែលមិនទាក់ទងដោយផ្ទាល់ទៅនឹងបទចោទនានានៅក្នុងសំណុំរឿង០០២/០១ អាចនឹងត្រូវបានទទួលយក ក៏ប៉ុន្តែថា "តាមពិត ការអនុវត្តនៅតាមមូលដ្ឋាននោះ គឺវាមិនត្រូវស្ថិតនៅក្នុងឯកសារគន្លឹះនៃការបង្ហាញឯកសារនៅក្នុងសវនាការនេះទេ"[11]។ ក្នុងអំឡុងពេលនៃការបង្ហាញឯកសារនៅថ្ងៃបន្ទាប់ សហព្រះរាជអាជ្ញាបានគូសបញ្ជាក់ថាមានឯកសារជាភ័ស្តុតាងខ្លះបង្ហាញឲ្យឃើញទាំងអត្ថិភាព និងការអនុវត្តគោលនយោបាយ JEC ដទៃទៀត និងថាភ័ស្តុតាងដូច្នេះអាចទទួលយកបាន ហើយអាចនឹងត្រូវបានពិចារណាយ៉ាងត្រឹមត្រូវដោយអង្គជំនុំជម្រះសាលាដំបូង[12]។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ភាគីអាចលើកយោងឯកសារណាដែល "មានព័ត៌មានដែលទំនងជានឹងចង្អុលបង្ហាញទាំងអំពីអត្ថិភាព និងការរីកចម្រើននៃគោលនយោបាយណាមួយ ហើយនឹងអំពីការអនុវត្តគោលនយោបាយនោះ" ប៉ុន្តែក៏បានអះអាងផងដែរថា ភាពពាក់ព័ន្ធនៃភ័ស្តុតាងដូច្នេះ ត្រូវបានកម្រិតត្រឹមអត្ថិភាព ឬការរីកចម្រើននៃគោលនយោបាយ"[13]។

## III. សំណើ

៨- តាំងដំបូងនៃសវនាការនេះមក អង្គជំនុំជម្រះសាលាដំបូងធ្លាប់បញ្ជាក់យ៉ាងច្បាស់លាស់រួចហើយថា ខ្លួននឹងស្តាប់ភ័ស្តុតាងក្នុងវិសាលភាពមួយយ៉ាងធំ ទាក់ទងនឹងរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ តួនាទីរបស់ជនជាប់ចោទ និងគ្រប់គោលនយោបាយរបស់ បកក ទាំងអស់ ដើម្បីឲ្យ (ក)

---

[9] **E124/7.3** ឧបសម្ព័ន្ធ: បញ្ជីកថាខណ្ឌទាំងឡាយ និងចំណែកនៃដីកាដំណោះស្រាយដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១។

[10] សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿងលេខ ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា ២០១៣, កថាខណ្ឌទី១១៨។

[11] **E1/212.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ២៥ មិថុនា ២០១៣, ត្រង់ 09.22.10 ដល់ 09.23.43។

[12] **E1/213.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ២៦ មិថុនា ២០១៣, ត្រង់ 11.15.35 ដល់ 11.21.44។

[13] **E1/213.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ២៦ មិថុនា ២០១៣, ត្រង់ 2013, 11.38.25 ដល់ 11.40.42។

ភ័ស្តុតាងនោះអាច "ផ្តល់នូវមូលដ្ឋានជាទូទៅមួយសម្រាប់បទចោទទាំងអស់ រួមទាំងបទចោទដែលនឹងត្រូវពិនិត្យក្នុងសវនាការនាពេលក្រោយៗទៀត"[14] ហើយ(ខ) ឧក្រិដ្ឋកម្មជាក់លាក់ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ត្រូវបានគេយល់ថា "ស្ថិតនៅក្នុងវង្វង់នៃបរិបទដ៏ទូលំទូលាយជាងនេះនៃសហកម្មឧក្រិដ្ឋកម្មរួម ដែលក្នុងនោះជនជាប់ចោទទាំងអស់សុទ្ធតែត្រូវបានចោទប្រកាន់ថា បានចូលរួម"[15]។ ក្នុងពេលជាមួយគ្នានេះ ដូចធ្វើការកត់សម្គាល់ពីខាងលើ អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ថា សាលក្រមនៅក្នុងសំណុំរឿងនេះ នឹងត្រូវកម្រិតត្រឹមបញ្ហាជាក់លាក់មួយចំនួនដែលពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០១។

៩- សហព្រះរាជអាជ្ញាយល់ឃើញថា សេចក្តីថ្លែង និងសេចក្តីសម្រេចផ្សេងៗខុសៗគ្នាជាច្រើន របស់អង្គជំនុំជម្រះសាលាដំបូងគឺមានន័យថា អង្គជំនុំជម្រះនឹងធ្វើការសម្រេចនៅក្នុងសាលក្រមរបស់ខ្លួនចំពោះតែគោលនយោបាយ JCE ណាដែលពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំ (ដំណាក់កាលទី១ និងទី២) និងការសម្លាប់ក្រោយការជម្លៀសនៅទួលពោធិ៍ជ្រៃប៉ុណ្ណោះ។ ការណ៍នេះមានន័យថា ចាំបាច់ត្រូវដាក់បញ្ចូលគោលនយោបាយ JCE ទាក់ទងនឹងការជម្លៀសដោយបង្ខំ ទាក់ទងនឹងខ្មាំង និងការកំណត់គោលដៅទៅលើមន្ត្រី និងទាហាន លន់ នល់។ សហព្រះរាជអាជ្ញាសន្និដ្ឋានបន្ថែមទៀតថា យ៉ាងហោចណាស់ គេត្រូវយល់ពីគោលបំណងអំពីបរិបទនៃការជម្លៀសដោយបង្ខំ ដែលចាំអង្គជំនុំជម្រះសាលាដំបូងត្រូវពិចារណាផងដែរ អំពីគោលនយោបាយរបស់ បកក ក្នុងការបង្កើតសហករណ៍។ ពិសេស ការជម្លៀសដោយបង្ខំលើកទីពីរ គឺមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងគោលនយោបាយ បកក ស្តីពីសហករណ៍ ការបង្ករបង្កើនផល និងការធ្វើឲ្យទៅជាទាសករនៃប្រជាជនស៊ីវិល។

១០- សហព្រះរាជអាជ្ញាជូនជាយោបល់ថា អង្គជំនុំជម្រះសាលាដំបូងមិនគួរធ្វើការរកឃើញ ដោយប្រាកដប្រជាទាក់ទងនឹងអង្គហេតុ ឬអង្គច្បាប់លើគោលនយោបាយនៃសហកម្មឧក្រិដ្ឋកម្មរួមដទៃទៀតថាមិនមានការជាប់ទាក់ទងដោយផ្ទាល់ទៅនឹងឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ នៅក្នុងសំណុំរឿងលេខ ០០២/០១នោះឡើយ ដូចជា គោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការផ្តោតមុខសញ្ញាទៅលើពុទ្ធសាសនិកជន, ជនជាតិចាម, និងជនជាតិវៀតណាម ជាដើម។ អង្គជំនុំជម្រះសាលាដំបូងមិនបានធ្វើការស្តាប់នូវភ័ស្តុតាងទាំងអស់ដែលទាក់ទងទៅនឹងកម្មវត្ថុនៃរឿងក្តីទាំងនោះទេ

---

[14] **E131** ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២, ១៨ តុលា ២០១១។

[15] **E284** សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿងលេខ ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា ២០១៣, កថាខណ្ឌទី១១៨។

។ ឧទាហរណ៍ដូចជា អង្គជំនុំជម្រះមិនបានស្តាប់ចម្លើយពីសាក្សីជាច្រើនដូចដែលបានស្នើសុំនៅក្នុងបញ្ជីសាក្សីសម្រាប់ពេលសវនាការរបស់សហព្រះរាជអាជ្ញាដែលពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងការធ្វើបាបទៅលើជនជាតិចាម, វៀតណាម និងទៅលើពុទ្ធសាសនិកជន[16] ដែលហេតុដូច្នេះទើបបានជាមេធាវីការពារក្តីមិនមានឱកាសដើម្បីធ្វើការតទល់ និងសួរដេញដោលចំពោះសាក្សីគន្លឹះនានារបស់ភាគីបដិបក្ខលើប្រធានបទទាំងនោះបាន។ ព្រមពេលជាមួយគ្នានេះ តាមកម្រិតដែលភ័ស្តុតាងទាក់ទងនឹងអត្ថិភាពនៃគោលនយោបាយផ្សេងៗទៀតទាំងនេះបានផ្តល់អំពីបរិបទដែលជាប់ពាក់ព័ន្ធគ្នានឹងបញ្ហានានានៅក្នុងសំណុំរឿងលេខ០០២/០១នោះ ភាគីទាំងឡាយគួរតែត្រូវបានអនុញ្ញាតឱ្យយោងទៅលើភ័ស្តុតាងទាំងនេះ ដូចដែលបានបង្ហាញជូនរួចមកហើយក្នុងពេលសវនាការនេះ នៅក្នុងសារណា និងនៅក្នុងសេចក្តីសន្និដ្ឋានបិទការពិភាក្សាដេញដោលរបស់ពួកគេ ហើយអង្គជំនុំជម្រះសាលាដំបូងអាចពិចារណាលើភ័ស្តុតាងទាំងនេះនៅក្នុងពេលពិភាក្សាសម្រេចរបស់ខ្លួន។

១១- អង្គជំនុំជម្រះសាលាដំបូងគួរតែដកដោយដាក់លាក់ផងដែរ ចេញពីការពិចារណារបស់ខ្លួន នូវការចោទប្រកាន់នានាដែលទាក់ទងទៅនឹងជនជាតិចាម ដែលត្រូវបានដាក់បញ្ចូលនៅក្នុងកថាខណ្ឌមួយចំនួនដែលពិភាក្សាអំពីការជម្លៀសប្រជាជនចេញដោយបង្ខំ ដំណាក់កាលទីពីរ[17]។ នៅក្នុងសវនាការនេះ ពុំមានសាក្សីណាម្នាក់ត្រូវបានធ្វើការស្តាប់ចម្លើយដែលពាក់ព័ន្ធនឹងការជម្លៀសចេញដោយបង្ខំនៃជនជាតិចាមនោះឡើយ។ ការចោទប្រកាន់ទាំងឡាយស្តីពីការជម្លៀសជនជាតិចាមចេញដោយបង្ខំគួរតែត្រូវបានស្តាប់ចម្លើយ និងសម្រេចជាផ្នែកនៅក្នុងការចោទប្រកាន់នានាដែលទូលំទូលាយជាងនេះពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញ និងការផ្តោតមុខសញ្ញាទៅលើជនជាតិចាមវិញនៅក្នុងសវនាការជំនុំជម្រះក្តីដែលរំពឹងថាអាចធ្វើទៅបាននាពេលអនាគត។ ហេតុដូច្នេះហើយ តាមការសន្មត អង្គជំនុំជម្រះសាលាដំបូង បានច្រានចោលនូវសំណើរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំឱ្យស្តាប់សាក្សីជនជាតិចាមចំនួនពីរនាក់ ដែលទាក់ទងទៅនឹងការជម្លៀសចេញដោយបង្ខំនៃក្រុមនោះ[18]។

---

[16] ឯកសារលេខ **E9/4.1** ឧបសម្ព័ន្ធទី១: សំណើសុំអំពីលំដាប់លេខរៀងនៃសាក្សីដែលត្រូវចូលបង្ហាញខ្លួននៅក្នុងសវនាការ (ជាប់ជាមួយនឹង "ការណែនាំ ស្តីពីការស្នើសុំដាក់សារណាជាលាយលក្ខណ៍អក្សរស្តីពីអញ្ញត្រកម្មបឋម" ( ឯកសារលេខE9/4)), ចុះថ្ងៃទី២០ មេសា ២០០៩ [ដែលស្នើសុំ សាក្សីចំនួន២១នាក់ ទាក់ទងនឹងការធ្វើបាបជនជាតិចាម, សាក្សីចំនួន២១នាក់ ទាក់ទងនឹងការធ្វើបាបជនជាតិវៀតណាម, សាក្សីចំនួន៨នាក់ទាក់ទងទៅនឹងការធ្វើបាបពុទ្ធសាសនិកជន និងយ៉ាងតិច សាក្សីចំនួន៧នាក់ទាក់ទងទៅនឹងបទបញ្ហាក្នុងការរៀបអាពាហ៍ពិពាហ៍]។

[17] ឯកសារលេខ **D427** ដីកាដំណោះស្រាយ, ចុះថ្ងៃទី១៥ កញ្ញា ២០១០, កថាខណ្ឌទី ២៦៦,២៦៨ និង២៨១។

[18] ឯកសារលេខ **E279** សំណើរបស់សហព្រះរាជអាជ្ញាសុំបញ្ជាក់អំពីកថាខណ្ឌមួយចំនួននៃដីកាដំណោះស្រាយដែលបានដាក់បញ្ចូលនៅក្នុងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ក្រោយថ្ងៃទី២៩ ខែមិនា ឆ្នាំ០១៣, ចុះថ្ងៃទី៨ មេសា ២០១៣ កថាខណ្ឌទី៥ ។ ឯកសារលេខ

១២- ហេតុនេះ សហព្រះរាជអាជ្ញាស្នើដល់អង្គជំនុំជម្រះសាលាដំបូង មេត្តាបញ្ជាក់ថា ខ្លួនមិនមានបំណងចង់ធ្វើការសម្រេចទាក់ទងនឹងអង្គហេតុ ឬធ្វើសេចក្តីសន្និដ្ឋានខាងអង្គច្បាប់ជាស្ថាពរ នៅក្នុងសាលក្រមនៃសំណុំរឿងលេខ០០២/០១ ស្តីពីគោលនយោបាយនៃសហកម្មខុក្រិដ្ឋកម្មរួមនានាដែលមិនជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់នៅក្នុងសំណុំរឿងនេះឡើយ- ជាក់ស្តែង គឺគោលនយោបាយដែលទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការផ្តោតមុខសញ្ញាទៅលើក្រុមពុទ្ធសាសនិកជន, ជនជាតិចាម និងជនជាតិវៀតណាម។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |

---

**E288/3** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាជាការឆ្លើយតបទៅនឹងសំណើរបស់មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ដែលសុំឲ្យផ្តល់ព័ត៌មាន មុនពេលប្រជុំស្តីពីការរៀបចំសវនាការ, ចុះថ្ងៃទី១០ មិថុនា ២០១៣, ត្រង់កថាខណ្ឌទី៥ និងទី៨-១០។